ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
លេខាធិការដ្ឋាននៃ គ.ជ.អ.ប
លេខ: ០២៥ គ.ជ.អ.ប លស

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៩

# ជម្រាបមក
## ឯកឧត្តមអភិបាលរាជធានី ខេត្ត
## និងជាប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត

**កម្មវត្ថុ** : ការរៀបចំសមាសភាពក្រុមការងារគណនេយ្យភាពរាជធានី ខេត្តឡើងវិញ និងបន្តដំណើរការប្រមូល និងដោះស្រាយពាក្យបណ្តឹង។

**យោង** :
- សេចក្តីសម្រេចលេខ ០១២ ស.ស.រ/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពជាតិ
- សេចក្តីណែនាំលេខ ០១៤ ស.ណ.ន/ គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង
- លិខិតលេខ ៥៧/គ.ជ.វ.វ ចុះថ្ងៃទី ២៣ខែឧសភា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្តីពីការបន្តដំណើរការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង។
- លិខិតលេខ ៣០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំឡើងវិញនូវក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត និងការបង្កើតក្រុមគាំទ្រក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមអភិបាលរាជធានី ខេត្ត និងជាប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ជ្រាបថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានផ្សព្វផ្សាយសេចក្តីណែនាំលេខ០១៤ ស.ណ.ន/ គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើត

ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ចាប់តាំងពីដើមខែមករា ឆ្នាំ២០០៩ មក ប៉ុន្តែរាជធានី ខេត្តមួយចំនួននៅមិនទាន់អនុវត្តការងារបានពេញលេញដូចបានកំណត់ក្នុងសេចក្តីណែនាំខាងលើនេះ ។

ដូច្នេះដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមធ្វើការណែនាំដល់រាជធានី ខេត្ត ដូចខាងក្រោម :

១-ត្រូវជំរុញដំណើរការរៀបចំសមាសភាពក្រុមការងារគណនេយ្យភាពរាជធានី ខេត្តឡើងវិញឱ្យស្របតាមខ្លឹមសារសេចក្តីណែនាំថ្មីលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវផ្ញើមកក្រុមការងារគណនេយ្យភាពជាតិឱ្យបានយ៉ាងយូរត្រឹម**ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩** ។

២-រៀបចំសមាសភាពក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត។ ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវកំណត់សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមគាំទ្រនេះ។ សូមបញ្ជាក់ថាសមាសភាពក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្តនេះ មិនមែនជាមន្ត្រីជំនួយការដែលត្រូវជ្រើសរើស ១-៣ រូបនោះឡើយ។ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមគាំទ្រនេះ ត្រូវផ្ញើមកក្រុមការងារគណនេយ្យភាពជាតិឱ្យបានមុន**ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០០៩**។

៣-ធ្វើការពិនិត្យ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយផ្អែកលើបទបញ្ជាផ្ទៃក្នុងដែលមានស្រាប់កន្លងមក។

៤-ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវធ្វើការប្រជុំឱ្យបានទៀងទាត់ដើម្បីពង្រឹង និងដោះស្រាយរាល់បណ្តឹងដែលប្រមូលបាន។

៥-ធ្វើការជ្រើសរើសមន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ចំនួន១-៣រូបឱ្យបានឆាប់រហ័ស ដើម្បីធ្វើការបណ្តុះបណ្តាលនៅ**ខែ កក្កដា ឆ្នាំ២០០៩** ដូចភ្ជាប់មកជាមួយ។

៦-ពិនិត្យឡើងវិញប្រអប់សំបុត្រគណនេយ្យភាព ដែលបានដាក់នៅទីតាំងផ្សេងៗក្នុងរាជធានី ខេត្ត និងវាយតម្លៃថាតើមានប្រអប់សំបុត្រចំនួនប៉ុន្មានដែលនៅប្រើការបាន និងតម្រូវការប្រអប់សំបុត្រដែលនឹងត្រូវផលិតបន្ថែម។ រាជធានី ខេត្តត្រូវធានាថាប្រអប់សំបុត្រដាក់នៅទីតាំងសាធារណៈជាអាទិភាព។

៧-ត្រូវធ្វើការប្រមូលព័ត៌មាន និងពាក្យបណ្តឹងពីគ្រប់ប្រភពទាំងអស់ឱ្យបានជាប្រចាំ ជាពិសេសពាក្យបណ្តឹងពីប្រអប់សំបុត្រគណនេយ្យភាព។ ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវបន្តដំណើរការដោះស្រាយពាក្យបណ្តឹងដែលប្រមូលបានឱ្យមានប្រសិទ្ធភាពដោយមិនត្រូវរង់ចាំការរៀបចំនីតិវិធីថ្មី។

៨-ធ្វើការរាយការណ៍ជាប្រចាំខែអំពីវឌ្ឍនភាពរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត មកក្រុមការងារគណនេយ្យភាពជាតិតាមរយៈទម្រង់របាយការណ៍ដែលភ្ជាប់មកជាមួយ។ កាលបរិច្ឆេទដាក់ជូនរបាយការណ៍ប្រចាំខែ **ត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់**។

៩-បំពេញសន្លឹកប័ណ្ណព័ត៌មានក្រុមការងារគណនេយ្យភាពរាជធានី ខេត្តសាមី និងផ្ញើមកក្រុមការងារគណនេយ្យភាពជាតិឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩។ ក្រុមការងារគណនេយ្យភាពជាតិ គ្រោងធ្វើការបោះពុម្ពសន្លឹកប័ណ្ណព័ត៌មានទាំងនេះជាដំណាក់កាល។ រាជធានី ខេត្តណាដែលមិនទាន់ច្បាស់អំពីឈ្មោះ និងលេខទូរស័ព្ទត្រូវទុកចន្លោះនេះឱ្យនៅទំនេរ។ រាជធានី ខេត្តត្រូវបន្តថតចម្លងសន្លឹកប័ណ្ណព័ត៌មាន (ស ខ្មៅ)ទាំងនេះ ដោយខ្លួនឯង ដើម្បីធានាថានៅតាមប្រអប់សំបុត្រគណនេយ្យភាពមានសន្លឹកប័ណ្ណព័ត៌មាននេះជាប្រចាំ។

១០-ធ្វើការផ្លាស់ប្តូរជាបន្ទាន់ចំពោះសមាជិកក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត រូបណាដែលបាត់បង់សមាជិកភាពពីក្រុមការងារគណនេយ្យភាពរាជធានី ខេត្តសាមី។ ប្រធានទីប្រឹក្សាគម្រោង (SPPA) ត្រូវជួយជំរុញការផ្លាស់ប្តូរសមាជិកថ្មីមកជំនួសឱ្យបានទាន់ពេល និងធានាថាសមាជិកថ្មីរូបនោះទទួលបានឯកសារពាក់ព័ន្ធគ្រប់គ្រាន់ និងការពន្យល់ណែនាំអំពីនីតិវិធីអនុវត្តការងាររបស់ក្រុមការងារគណនេយ្យភាព។

អាស្រ័យហេតុបានជម្រាបជូនខាងលើ សូមឯកឧត្តមចាត់ចែងអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

**លេខាធិការដ្ឋាន គ.ជ.អ.ប**
**ប្រធាន**

សរ៉ា...

**ចម្លងជូន :**

-សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់
"សហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ